# លក្ខន្តិកៈ
# សហព័ន្ធកីឡាប៊ូល និងប៉េតង់កម្ពុជា

## ជំពូក I: គោលបំណង និងសមាសភាព និងរចនាសម្ព័ន្ធ

**ប្រការ១** : សហព័ន្ធហៅថា "សហព័ន្ធកីឡាប៊ូល និងប៉េតង់កម្ពុជា" អក្សរកាត់ "ស.ប.ប.ក" ជាអង្គការសង្គមកីឡាថ្នាក់ជាតិ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩២ ក្នុងគោលបំណងដូចតទៅៈ

- អភិវឌ្ឍ ផ្សព្វផ្សាយវិញ្ញាសាកីឡាប៊ូល និងកីឡាប៉េតង់កម្ពុជា។
- រៀបចំក្លឹប-សមាគម-សម្ព័ន្ធ កីឡាប៊ូល និងប៉េតង់នៅកម្ពុជា និងលើកទឹកចិត្តដល់ការកសាងបណ្តាក្លឹប-សមាគម និងសម្ព័ន្ធថ្មីៗ។
- ធ្វើជាតំណាងប្រទេសកម្ពុជានៅក្នុងសហព័ន្ធកីឡាប៉េតង់និងកីឡាប្រ៉ូវ៉ង់ស្បាល់អន្តរជាតិនិងសហពន្ធ័កីឡាប៊ូលនិងប៉េតង់អាស៊ី។ រយៈពេលនៃសហព័ន្ធពុំមានកំណត់។
- សហព័ន្ធមិនប្រកាន់និន្នាការនយោបាយ ជនជាតិ ឬសាសនាអ្វីឡើយ។
- សហព័ន្ធមានទីស្នាក់ការនៅភ្នំពេញ "ពហុកីឡដ្ឋានជាតិ" ប្រអប់សំបុត្រលេខ ១០១ ភ្នំពេញ។
- បដិរូបសហព័ន្ធមានចែងដូចខាងក្រោម (**ឧបសម្ព័ន្ធ ១**)

**ប្រការ ២** : **សកម្មភាពរបស់សហព័ន្ធមានជាអាទិ៍:**

ក- បកប្រែជាភាសារខ្មែរ និងចែកផ្សាយនូវបទបញ្ញាអន្តរជាតិនៃកីឡា ប៊ូលនិងប៉េតង់និងព្រឹត្តិប័ត្រទាំងឡាយណាដែលមានសារៈសំខាន់ ដល់កីឡាប៊ូល និងប៉េតង់។

ខ- បង្កើតក្លឹប-សមាគម-សម្ព័ន្ធកីឡាប៊ូល និងប៉េតង់ថ្នាក់រាជធានី-ខេត្ត និងក្រសួងមន្ទីរជាសមាជិកសកម្ម (Membre affillié) និងសមាជិកចូលរួម (Membre Associé) ចំពោះសមាគមដែលពុំមានសញ្ញាតិជាកម្ពុជា។

គ- រៀបចំកម្មវិធីប្រចាំឆ្នាំសំរាប់ការប្រកួតជំរើសជើងឯកទូទាំងប្រទេសនិងពានរង្វាន់កីឡាប៊ូល និងប៉េតង់។

ឃ- ចាត់តាំងគណៈប្រតិភូកីឡាកម្ពុជាចូលរួមប្រកួតជាលក្ខណៈអន្តរជាតិ។

**ប្រការ ៣** :

សហព័ន្ធកីឡាប៊ូល និងប៉េតង់កម្ពុជា ចែកចេញជាក្លឹប-សមាគម និងសម្ព័ន្ធដូចមានចែងក្នុងប្រការ ២។

## **ជំពូក II: ការគ្រប់គ្រង និងដំណើរការសហព័ន្ធ**

**ប្រការ ៤**: សហព័ន្ធដឹកនាំដោយគណៈកម្មាធិការប្រតិបត្តិដែលប្រសូតចេញពីការបោះឆ្នោត សមាជិកគណៈកម្មាធិការប្រតិបត្តិដែលបានបញ្ចប់អាណត្តិរួចអាចឈរឈ្មោះបោះឆ្នោតជាថ្មីវិញបាន។ ក្នុងករណីអវត្តមាន សមាជិកគណៈកម្មាធិការប្រតិបត្តិលើសពីពាក់កណ្តាល មហាសន្និបាតត្រូវកោះប្រជុំជ្រើសរើសសមាជិកថ្មីជំនួសដើម្បីបន្តការងារបញ្ចប់អាណត្តិ។

**ប្រការ ៥**: មហាសន្និបាត ជាអង្គការដឹកនាំកំពូលរបស់សហព័ន្ធ។ មហាសន្និបាតត្រូវការចូលរួមពីសមាជិកដែលមានចែងក្នុងប្រការ២ចំនុច ខ។

- គណៈកម្មាធិការប្រតិបត្តិត្រូវបានអញ្ជើញចូលរួមមហាសន្និបាតក្នុងនាមសមាជិកពុំមានសិទ្ធិបោះឆ្នោត លើកលែងតែសមាជិកនោះតំណាងឲ្យសមាគមជាសមាជិកសកម្ម។
- មហាសន្និបាតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិដែលមានសមាសភាពយ៉ាងតិចប្រាំបួននាក់។

**ប្រការ ៦**: មហាសន្និបាតសាមញ្ញប្រចាំឆ្នាំ ត្រូវបានប្រារព្ធធ្វើឡើងមួយឆ្នាំម្តងដើម្បីៈ

- ស្តាប់របាយការណ៍ គោលគំនិត យុទ្ធសាស្ត្ររបស់ប្រធាន
- ពិនិត្យ និងអនុម័តលើរបាយការណ៍ និងទិសដៅស្តីពីសកម្មភាពរបស់គណកម្មាធិការប្រតិបត្តិដែលរៀបចំឡើយដោយអគ្គលេខាធិការ ។
- ពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ នៃការិយបរិច្ឆេទកន្លងមក និងផែនការឆ្នាំបន្ត ។

**ប្រការ ៧**: មហាសន្និបាតអាចកោះប្រជុំជាវិសាមញ្ញបានតាមសំណើររបស់សមាជិកមួយភាគបី ឬ តាមសំណើររបស់គណៈកម្មាធិការប្រតិបត្តិលើស ៥០% ។

**ប្រការ ៨**: មហាសន្និបាតអាចពិភាក្សាបានតែលើបញ្ហាដែលមានចែងនៅក្នុងរបៀបវារៈ

- សំណើដែលត្រូវលើកឡើងក្នុងមហាសន្និបាត ត្រូវផ្ញើជូនមកអគ្គលេខាធិការដ្ឋាន យ៉ាងយូរ ៣០ថ្ងៃ មុនពេលបើកសម័យប្រជុំ ។
- កាលបរិច្ឆេទនៃសម័យប្រជុំត្រូវជូនដំណឹងដល់សមាជិកយ៉ាងតិច ១៥ថ្ងៃមុន វៀរលែងតែករណីបន្ទាន់ដោយត្រូវភ្ជាប់ខ្លឹមសារនៃរបៀបវារៈទៅជាមួយ ។

**ប្រការ ៩**: មហាសន្និបាតអាចពិភាក្សាជាផ្លូវការបាន លុះត្រាតែមានវត្តមានសមាជិកយ៉ាងតិច ហាសិបភាគរយបូកមួយ ។ សេចក្តីសម្រេចអាចចាត់ទុកជាបានការលុះត្រាមាន សំលេងគាំទ្រភាគច្រើននៃចំនួនវត្តមានក្នុងសម័យប្រជុំ ។

**ប្រការ ១០**: នៅក្នុងចន្លោះសម័យប្រជុំមហាសន្និបាត សហព័ន្ធដឹកនាំដោយគណៈកម្មាធិការប្រតិបត្តិ ដែលបោះឆ្នោតដោយមហាសន្និបាតសហព័ន្ធ

(ក) សមាសភាពគណៈកម្មាធិការប្រតិបត្តិរួមមានៈ

- ប្រធាន ០១ រូប
- អនុប្រធាន ០១ រូប ឬច្រើនរូប
- អគ្គលេខាធិការ ០១ រូប
- អគ្គលេខាធិការរង ០១ រូប ឬច្រើនរូប
- អគ្គហេរញ្ញិក ០១ រូប
- សមាជិក មួយចំនួន

(ខ) គណៈកម្មាធិការប្រតិបត្តិសហព័ន្ធដែលបានបញ្ចប់អាណត្តិរបស់ខ្លួនជាស្ថាពរត្រូវ បានទទួលគោរម្យងារ"កិត្តិយសមួយជីវិត"ដោយស្វ័យប្រវត្តិ។

**ប្រការ ១១**: គណៈកម្មាធិការប្រតិបត្តិរួមប្រជុំយ៉ាងតិចបីខែម្តង ។ កិច្ចប្រជុំអាចពិភាក្សាបានលុះ ត្រាតែមានវត្តមានសមាជិកលើសពីហាសិបភាគរយៈ

- សេចក្តីសំរេចចាត់ទុកជាបានការ លុះត្រាតែមានសម្លេងគាំទ្រភាគច្រើននៃ សមាជិកវត្តមាន។
- រាល់កិច្ចប្រជុំរបស់គណៈកម្មាធិការត្រូវកោះអញ្ជើញដោយប្រធានឬតំណាង យ៉ាងតិចប្រាំពីរថ្ងៃមុនពេលប្រជុំវៀរលែងតែក្នុងករណីបន្ទាន់។
- លិខិតអញ្ជើញប្រជុំត្រូវបញ្ជាក់របៀបវារៈនៃអង្គប្រជុំ។
- រាល់កិច្ចប្រជុំត្រូវមានកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយលេខាធិការនិង ប្រធានអង្គប្រជុំ។
- អគ្គលេខាធិការជាអ្នករក្សាទុករាល់ឯកសារទាំងអស់របស់សហពន្ធ័។

**ប្រការ ១២:** គណៈកម្មាធិការអចិន្ត្រៃយ៍មួយត្រូវបានបង្កើតឡើងចំណុះគណៈកម្មាធិការប្រតិបត្តិ ដែលមានសមាសភាពចំនួនពី ០៧ រូបទៅ ០៩ រូប ។

១- អនុប្រធានទី ១ ០១ រូប

២- អនុប្រធាន ០២ រូប

៣- អគ្គលេខាធិការ ០១ រូប

៤- អគ្គហេរញ្ញិក ០១ រូប

៥- អគ្គលេខាធិការរង ០១ រូប

៦- សមាជិក ០៣ រូប

គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវប្រជុំការងារចាំបាច់នានានៅចន្លោះសម័យប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវសុំការអនុម័តពីគណៈកម្មាធិការប្រតិបត្តិ។

**ប្រការ ១៣:**

គណៈកម្មាធិការប្រតិបត្តិបង្កើតគណៈកម្មាធិការជំនាញមួយចំនួនជាជំនួយការ។

**ប្រការ ១៤:**

អគ្គលេខាធិការដ្ឋានជាការិយាល័យជំនួយការឲ្យគណៈកម្មាធិការប្រតិបត្តិ។សមាសភាពក្នុងអគ្គលេខាធិការដ្ឋានត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់សហព័ន្ធ។

## ជំពូក III :ហិរញ្ញវត្ថុ

**ប្រការ ១៥ :** ប្រភពចំណូលរបស់សហព័ន្ធបានមកពីៈ

- ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល
- វិភាគទានរបស់សមាជិក
- ថ្លៃសិទ្ធិចូលរួមប្រកួត
- ថ្លៃសិទ្ធិផ្តល់អត្តសញ្ញាណប័ណ្ណកីឡា
- អំណោយ លទ្ធច្ច័យទាន ដែលមហាសន្និបាតអនុម័តទទួលយក។
- ចំណូលផ្សេងៗទៀតដែលគណៈកម្មាធិការប្រតិបត្តិ បណ្តាលសមាគម-ក្លឹប ឬសម្ព័ន្ធនានារកបាន។
- ចំនួនទឹកប្រាក់វិភាគទាន និងសិទ្ធិ នានាត្រូវកំណត់ដោយមហាសន្និបាត។

## ជំពូក IV អត្តសញ្ញាណប័ណ្ណកីឡា

**ប្រការ ១៦ :** កីឡាករម្នាក់ៗត្រូវមានអត្តសញ្ញាណប័ណ្ណកីឡាដែលចេញដោយសហព័ន្ធ។

- អាចចូលរួមក្នុងការប្រកួតជំរើសជើងឯកទូទាំងប្រទេស និងពានរង្វាន់ចំពោះតែកីឡាករដែលមានអត្តសញ្ញាណប័ណ្ណកីឡាចេញដោយសហព័ន្ធកីឡាប៊ូល និងប៉េតង់កម្ពុជាតែប៉ុណ្ណោះ ។

**ប្រការ ១៧:** សហព័ន្ធនឹងចេញអត្តសញ្ញាណប័ណ្ណកីឡាសំគាល់ឲ្យកីឡាកររៀងរាល់ឆ្នាំ ។ ការបង់ថ្លៃសិទ្ធិមានពីរប្រភេទដូចមានចែងក្នុងប្រការ២ ចំណុច "ខ" ។ អត្តសញ្ញាណប័ណ្ណកីឡាគឺសមាគម-សម្ព័ន្ធ របស់កីឡាករជាអ្នកចេញ ។ កីឡាករត្រូវបង់ទៅតាមវេនរបស់ខ្លួនឲ្យសមាគម-ក្លឹបឬសម្ព័ន្ធទទ្ទឹមនឹងពេលដែលត្រូវបង់វិភាគទានប្រចាំឆ្នាំ ។

**ប្រការ ១៨:** សហព័ន្ធអាចរៀបចំបទបញ្ជាផ្ទៃក្នុងស្តីពីការគ្រប់គ្រងអត្តសញ្ញាណប័ណ្ណកីឡានេះ។

## ជំពូក V : វិន័យ

**ប្រការ ១៩:** ប្រសិនបើមានក្លឹប-សមាគម-សម្ព័ន កីឡាករ-កីឡាការិនី ឬមន្ត្រីកីឡាណាម្នាក់ល្មើសនិងលក្ខន្តិកៈ និងបទបញ្ជារបស់សហព័ន្ធនោះ គណៈកម្មាធិការប្រតិបត្តិមានសិទ្ធិសម្រេចដាក់ទោសទណ្ឌពិន័យទៅតាមកំរិតទោស ។

**ប្រការ ២០:** កម្រិតពិន័យទាំងឡាយមានៈ

- ការស្តីបន្ទោស
- ការព្យួរជើង
- ការលប់ឈ្មោះចេញពីសហព័ន្ធ
- កីឡាករដែលមានអត្តសញ្ញាណប័ណ្ណសំគាល់ "Licence" របស់សមាគម សម្ព័ន្ធណាមួយដែលត្រូវបានទទួលទោសព្យួរជើងអាចចូលរួមប្រកូតបានតែក្នុងការប្រកូតសាមញ្ញធម្មតា តែពុំអាចចូលរួមប្រកួតក្នុងការប្រកួតជំរើសជើងឯកបានឡើយ ។ ក្នុងករណីមានកំហុសធ្ងន់ធ្ងរ ត្រូវកោះប្រជុំមហាសន្និបាតវិសាមញ្ញដើម្បីសំរេច ។

**ប្រការ ២១:** បណ្តាសមាគម-ក្លឹប-សម្ព័ន ចំណុះមានសិទ្ធិសុំឧទ្ធរណ៍ចំពោះការសំរេចដាក់ពិន័យរបស់គណៈកម្មាធិការប្រតិបត្តិនៅចំពោះមុខអង្គមហាសន្និបាត ។

## **ជំពូក VI : ការកែប្រែលក្ខន្តិកៈ និងសិទ្ធិតវ៉ា**

**ប្រការ ២២ :** លក្ខន្តិកៈនេះអាចកែប្រែបានដោយមហាសន្និបាតតាមសំណើរបស់គណៈកម្មាធិការប្រតិបត្តិឬរបស់សមាជិកសកម្ម ១/៣ ។ លិខិតអញ្ជើញចូលរួមមហាសន្និបាតត្រូវភ្ជាប់មកជាមួយនូវសំណើកែប្រែលក្ខន្តិកៈដោយមានយោបល់របស់គណៈកម្មាធិការប្រតិបត្តិលើសាមីសំណើ ។

**ប្រការ ២៣:** -មហាសន្និបាតគឺជាសមត្ថកិច្ចនីតិវិនិច្ឆ័យចុងក្រោយក្នុងការសំរេចរាល់ករណីដែលសមាជិកបានដាក់ជូន ។

-សេចក្តីសំរេចរបស់មហាសន្និបាត គឺជាសេចក្តីសម្រេចចុងក្រោយដោយពុំមានសិទ្ធិឧទ្ធរណ៍ឡើយ ។

## **ជំពូក VII : អវសានប្បញ្ញត្តិ**

**ប្រការ ២៤ :** លក្ខន្តិកៈនេះត្រូវបានមហាសន្និបាតរបស់សហព័ន្ធកីឡាប៊ូល និងប៉េតង់កម្ពុជាអនុម័តត្រូវចូលជាធរមានប្បញ្ញត្តិជាបន្ទាន់ ។

**ប្រការ ២៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីលក្ខន្តិកៈនេះត្រូវចាត់ទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០១៧

**ជ.ប្រធានសហពន្ធ័កីឡាប៊ូលនិងប៉េតង់កម្ពុជា**

**អនុប្រធានទី១** | **លេខាធិការ**

**ឯកឧត្តមព្រហ្ម ឌិន** | **អ៊ុន គិមស្រ៊ុន**